ក្រុមមេធាវី ខេមឡ
CAMLAW GROUP

# ច្បាប់
# ស្តីពី
# ផ្លូវថ្នល់

២០១៨



រៀបចំភក្តីឡង់ PHEAKDEYLAW.COM.KH

# ព្រះរាជក្រម

នស/រកម/០៥១៤/០០៨

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខនស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីផ្លូវថ្នល់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៤ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្តីពី

# ផ្លូវថ្នល់

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងគ្រប់គ្រង អភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងធានាសុវត្ថិភាពចរាចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ច្បាប់នេះមានគោលដៅដូចតទៅ ៖

- ការពារទ្រព្យសម្បត្តិសាធារណៈ ការពារនិងលើកកម្ពស់គុណភាពផ្លូវថ្នល់ រក្សាសណ្តាប់ធ្នាប់ សម្រួលការធ្វើដំណើរនិងការដឹកជញ្ជូនតាមផ្លូវគោក
- កំណត់គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍសម្រាប់សាងសង់ ជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ព្រមទាំងកំណត់វិធាននិងបទប្បញ្ញត្តិបច្ចេកទេស
- ជំរុញនិងលើកទឹកចិត្តឲ្យវិស័យឯកជនចូលរួមក្នុងការសាងសង់ ការជួសជុល ការថែទាំ និងការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់
- ជំរុញកិច្ចសហប្រតិបត្តិការនិងសមាហរណកម្មជាតិ តំបន់ អនុតំបន់ និងអន្តរជាតិ លើវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់
- លើកទឹកចិត្តចំពោះការសិក្សាស្រាវជ្រាវបច្ចេកទេសនិងការផ្ទេរបច្ចេកវិជ្ជាថ្មីៗ ដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- អភិវឌ្ឍធនធានមនុស្សក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៣.-**

ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះរាល់សកម្មភាពពាក់ព័ន្ធនឹងវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

វាក្យសព្ទបច្ចេកទេសដែលប្រើប្រាស់ក្នុងច្បាប់នេះ មានកំណត់នៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ ។

## ជំពូកទី ២
## សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់

**មាត្រា ៥.-**

សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ ត្រូវបានកំណត់ដូចខាងក្រោម ៖

១- ក្រសួងសាធារណការនិងដឹកជញ្ជូន មានសមត្ថកិច្ចគ្រប់គ្រងលើផ្លូវល្បឿនលឿន ផ្លូវជាតិ ផ្លូវខេត្ត និងផ្លូវផ្សេងទៀតដែលរាជរដ្ឋាភិបាលប្រគល់ឲ្យ ។

២- ក្រសួងអភិវឌ្ឍន៍ជនបទមានសមត្ថកិច្ចគ្រប់គ្រងលើផ្លូវជនបទ និងផ្លូវផ្សេងទៀតដែលរាជ-រដ្ឋាភិបាលប្រគល់ឲ្យ ។

៣- រដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថកិច្ចគ្រប់គ្រងលើផ្លូវរាជធានី ផ្លូវក្រុង ផ្លូវទីប្រជុំជននានាក្នុងខេត្ត ដែលត្រូវបានកសាងជួសជុលថែទាំដោយប្រើប្រាស់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងថវិកាដែលបានកៀរគរពីប្រភពផ្សេងទៀត និងផ្លូវផ្សេងទៀតតាមការផ្ទេរមុខងារពីក្រសួង សាធារណការនិងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងផ្លូវផ្សេងទៀតក្រោយពីមានការសម្រេចឯកភាពពីរាជរដ្ឋាភិបាល ។

ការបែងចែកសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ផ្សេងទៀត ត្រូវកំណត់ដោយរាជរដ្ឋាភិបាល ។

**មាត្រា ៦.-**

រដ្ឋបាលថ្នាក់ក្រោមជាតិ មានសិទ្ធិក្នុងការគ្រប់គ្រងនិងចាត់ចែងផ្លូវថ្នល់ក្នុងសមត្ថកិច្ចរបស់ខ្លួនស្របតាមចំណុចទី ៣ នៃមាត្រា ៥ នៃច្បាប់នេះ ។ រាល់ការធ្វើផែនការ ការអភិវឌ្ឍផ្លូវថ្នល់ ការសិក្សាគម្រោងប្លង់ ដែលទាមទារបច្ចេកទេសខ្ពស់រដ្ឋបាលថ្នាក់ក្រោមជាតិអាចសុំការឯកភាពពីក្រសួងសាធារណការនិងដឹកជញ្ជូន ឬក្រសួងអភិវឌ្ឍន៍ជនបទទៅតាមជំនាញរបស់ក្រសួង និងត្រូវគោរពតាមបទប្បញ្ញត្តិបច្ចេកទេស បទប្បញ្ញត្តិនគរូបនីយកម្ម និងបេតិកភណ្ឌ និងស្របតាមបទប្បញ្ញត្តិ នៃច្បាប់នេះ ។

## ជំពូកទី ៣
## ប្រភេទ ឈ្មោះ និងចំណាត់ថ្នាក់ផ្លូវថ្នល់

**មាត្រា ៧.-**

ផ្លូវថ្នល់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានបែងចែកជាប្រភេទដូចខាងក្រោម ៖

១- ផ្លូវល្បឿនលឿន ។

២- ផ្លូវជាតិ ។

៣- ផ្លូវខេត្ត ។

៤- ផ្លូវជនបទ ។

៥- ផ្លូវរាជធានី ផ្លូវក្រុង និងផ្លូវទីប្រជុំជននានាក្នុងខេត្ត ។

៦- ប្រភេទផ្លូវផ្សេងៗទៀតដែលកំណត់ដោយរាជរដ្ឋាភិបាល ។

**មាត្រា ៨.-**

ផ្លូវល្បឿនលឿន ផ្លូវជាតិ ផ្លូវខេត្ត ផ្លូវរាជធានី ផ្លូវក្រុង ផ្លូវទីប្រជុំជននានាក្នុងខេត្ត និង ផ្លូវជនបទ ត្រូវមានឈ្មោះផ្លូវ និងឬលេខផ្លូវ និង ត្រូវកំណត់ចម្ងាយជាក់លាក់ ។

ការដាក់ឈ្មោះផ្លូវ ឬការដាក់លេខផ្លូវត្រូវកំណត់ដូចខាងក្រោម ៖

១- ឈ្មោះផ្លូវអាចដាក់ជាឈ្មោះវីរបុរស ឥស្សរជន សប្បុរសជន ឈ្មោះពីប្រវត្តិសាស្ត្រ ឈ្មោះតាមភូមិសាស្ត្រធម្មជាតិ ឈ្មោះតាមវប្បធម៌ ឈ្មោះពីបុរាណ ឈ្មោះតាមទម្លាប់ ។

២- លេខផ្លូវត្រូវដាក់តាមវិធីសាស្ត្រមួយ ដែលអាចកំណត់ច្បាស់លាស់នូវទីតាំងផ្លូវ ប្រភេទផ្លូវ និងអាទិភាពផ្លូវ ។

៣- ឈ្មោះផ្លូវឬលេខផ្លូវ ដែលតភ្ជាប់ទៅនឹងផ្លូវអន្តរជាតិ ត្រូវដាក់តាមការសម្រេចពីរាជរដ្ឋាភិបាល ។ ផ្លូវដែលតភ្ជាប់ទៅនឹងផ្លូវអន្តរជាតិ ត្រូវដាក់ទាំងឈ្មោះ ទាំងលេខផ្លូវក្នុងប្រទេស និងទាំងឈ្មោះទាំងលេខផ្លូវអន្តរជាតិ ។

បែបបទនិងនីតិវិធីនៃការដាក់ឈ្មោះផ្លូវ ឬលេខផ្លូវ និងការកែប្រែឈ្មោះផ្លូវ ឬលេខផ្លូវត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៩.-**

សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ ត្រូវរៀបចំបែងចែកចំណាត់ថ្នាក់ផ្លូវថ្នល់ដោយផ្អែកទៅលើការគ្រប់គ្រងភូមិសាស្ត្ររដ្ឋបាល មុខងារនៃផ្លូវថ្នល់ និងបទប្បញ្ញត្តិបច្ចេកទេសផ្លូវថ្នល់ និងត្រូវធ្វើបញ្ជីសារពើភណ្ឌផ្លូវថ្នល់ ដោយពិគ្រោះយោបល់ជាមួយសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ពាក់ព័ន្ធក្នុងរយៈពេលយ៉ាងយូរបំផុត ៥ (ប្រាំ) ឆ្នាំម្តង ដើម្បីធ្វើចំណាត់ថ្នាក់ផ្លូវថ្នល់ និងកែប្រែចំណាត់ថ្នាក់ផ្លូវថ្នល់ ។

មុខងារនៃផ្លូវថ្នល់ និងការធ្វើចំណាត់ថ្នាក់ផ្លូវថ្នល់ និងការកែប្រែចំណាត់ថ្នាក់ផ្លូវថ្នល់ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៤
## ការអភិវឌ្ឍ និងការថែទាំផ្លូវថ្នល់

**មាត្រា ១០.-**

សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ ត្រូវរៀបចំផែនការមេអភិវឌ្ឍន៍ផ្លូវថ្នល់ គម្រោងប្លង់ និងកំណត់អាទិភាពគម្រោងសាងសង់ ស្ដារឡើងវិញ កែលម្អ ពង្រីក និងថែទាំផ្លូវថ្នល់ ព្រមទាំងសកម្មភាព អភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ផ្សេងទៀត ដើម្បីដាក់ស្នើសុំគោលការណ៍ឯកភាពពីរាជរដ្ឋាភិបាល ។

បែបបទ និងវិធីសាស្ត្រ នៃការបង្កើតផែនការមេអភិវឌ្ឍន៍ផ្លូវថ្នល់ ការរៀបចំគម្រោងប្លង់ និងការកំណត់អាទិភាពគម្រោង ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងសាធារណការ និង [illegible] និងរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ។

**មាត្រា ១១.-**

ចំពោះរាល់ការសាងសង់ ការពង្រីកផ្លូវថ្នល់ ផ្លូវប្រសព្វ ផ្លូវជាន់គ្នា ស្ពាន ស្ពានអាកាស ស្ពាន

វែលង ផ្លូវក្នុងដី ឬរូងក្រោមដី ផ្លូវក្រោមផ្ទៃទឹក ផ្លូវលើ ឬក្រោមផ្លូវអេយស្ម័យយាន ជាពិសេសផ្លូវមានចរាចរណ៍កកស្ទះជារៀងរាល់ថ្ងៃ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាសាធារណៈ និងបញ្ជូនសំណៅប្លង់សាងសង់ដល់សមត្ថកិច្ចពាក់ព័ន្ធ ។ ក្នុងករណីនេះ ប្រសិនបើការសាងសង់ ឬការពង្រីកផ្លូវថ្នល់នោះប៉ះពាល់ដល់កម្មសិទ្ធិស្របច្បាប់ កម្មសិទ្ធិករអាចទទួលបានសំណងសមរម្យនិងយុត្តិធម៌ ស្របតាមច្បាប់ស្តីពីអស្សាមិករណ៍ ។

**មាត្រា ១២.-**

រាល់ការសាងសង់លើដីសម្រាប់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ជាពិសេសលើដីចំណីផ្លូវជាលក្ខណៈអចិន្ត្រៃយ៍ត្រូវបានហាមឃាត់ លើកលែងតែការសាងសង់ក្នុងគម្រោងចាំបាច់មួយចំនួនដូចជាបរិក្ខារបម្រើឲ្យវិស័យការពារជាតិ សន្តិសុខជាតិ បរិក្ខារបម្រើឲ្យការគ្រប់គ្រង ឬការសាងសង់ផ្លូវនិងបរិក្ខារសំណង់សេវាសាធារណៈផ្សេងៗទៀត ដែលត្រូវស្នើសុំការឯកភាពជាគោលការណ៍ពីរាជរដ្ឋាភិបាលតាមសំណើរបស់សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ ។

ដីចំណីផ្លូវ អាចប្រើប្រាស់បានសម្រាប់គោលបំណងផ្សេងៗជាលក្ខណៈបណ្តោះអាសន្ន ដោយមិនត្រូវធ្វើប៉ះពាល់ដល់បរិក្ខារនិងសំណង់ផ្សេងៗសម្រាប់សុវត្ថិភាពចរាចរណ៍ផ្លូវថ្នល់ឡើយ ។

ការគ្រប់គ្រងលើការប្រើប្រាស់ដីចំណីផ្លូវនៅតាមបណ្តាញផ្លូវថ្នល់ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៣.-**

សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ ឬផ្នែកឯកជនដែលបានទទួលសិទ្ធិសាងសង់ ឬអភិវឌ្ឍផ្លូវថ្នល់ថ្មីត្រូវបំពាក់បរិក្ខារផ្លូវថ្នល់ឲ្យបានគ្រប់គ្រាន់ និងស្របតាមបទប្បញ្ញត្តិបច្ចេកទេសមុននឹងដាក់ឲ្យប្រើប្រាស់ជាផ្លូវការ ។

**មាត្រា ១៤.-**

ការសាងសង់ផ្លូវថ្នល់ថ្មី ត្រូវត្រៀមបម្រុងទុកដីចំណីផ្លូវនិងដីសម្រាប់សំណង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ចាំបាច់ផ្សេងៗទៀត ។

ដោយឡែកការសាងសង់ផ្លូវថ្នល់ក្នុងទីក្រុង បុរី និងតំបន់អភិវឌ្ឍន៍ថ្មី ត្រូវសាងសង់ផ្លូវសម្រាប់ថ្មើរជើង ផ្លូវសម្រាប់ជនពិការ និងសំណង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ចាំបាច់ផ្សេងៗទៀត ដែលធានាបាននូវសុវត្ថិភាពចរាចរណ៍ ។

ការត្រៀមបម្រុងទុកដីចំណីផ្លូវ និងដីសម្រាប់សំណង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ខាងលើ ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងត្រូវផ្ញើសំណៅប្លង់នៃការបម្រុងទុកដីចំណីផ្លូវ និងដីសម្រាប់សំណង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ទាំងនោះ ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងមហាផ្ទៃ ដើម្បីចូលរួមសហការចាត់វិធានការការពារ ។

**មាត្រា ១៥.-**

ចំពោះរាល់ការសាងសង់ផ្លូវថ្នល់ ផ្លូវប្រសព្វ ផ្លូវប្រសព្វក្នុងលំហ ផ្លូវជាន់គ្នា ស្ពានអាកាស ស្ពានលែង ផ្លូវរូងក្រោមដី ផ្លូវក្រោមទឹក ឬផ្លូវជួបគ្នារវាងផ្លូវថ្នល់និងផ្លូវអយស្ម័យយាន ត្រូវសាងសង់ទៅតាមបទប្បញ្ញត្តិបច្ចេកទេស ដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់នេះ ។

**មាត្រា ១៦.-**

ផ្លូវថ្នល់ត្រូវតែទទួលបានការថែទាំជាទៀងទាត់ ។ ការថែទាំផ្លូវថ្នល់ត្រូវមានលក្ខណៈជាប្រភេទការថែទាំខួប ការថែទាំប្រចាំ និងការជួសជុលបន្ទាន់ ។

ផ្លូវថ្នល់ដែលដាក់ឲ្យប្រើប្រាស់ជាផ្លូវការ ត្រូវគ្រប់គ្រងនិងថែទាំស្របតាមបទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីជួសជុលថែទាំដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់នេះឲ្យបានត្រឹមត្រូវ ដោយត្រូវថែរក្សាស្ថានភាពនៃផ្លូវថ្នល់ឲ្យបានល្អ ធ្វើសវនកម្ម និងត្រូវធ្វើការត្រួតពិនិត្យជាប្រចាំនូវសមាសភាពហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ។

**មាត្រា ១៧.-**

សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ ត្រូវរៀបចំឲ្យមានស្ថានីយថ្លឹងយានយន្តនៅចំណុចចាំបាច់ ស្ថានីយចំណតរថយន្ត ទីសំចតរថយន្ត ស្ថានីយឈប់សម្រាក ទីតាំងលំហែ នៅតាមបណ្តាញផ្លូវថ្នល់ ។ ក្នុងករណីចាំបាច់ សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ អាចសាងសង់ស្ថានីយប្រមូលចំណូល នៅតាមបណ្តាញផ្លូវថ្នល់ ដើម្បីបម្រើឲ្យសេវាដឹកជញ្ជូន ការពារនិងថែទាំផ្លូវថ្នល់ ក្រោយពីមានការឯកភាពពីរាជរដ្ឋាភិបាល ។

រាល់បណ្តាសំណង់ដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើ ត្រូវគោរពតាមបទប្បញ្ញត្តិ បច្ចេកទេសដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់នេះ ។

**មាត្រា ១៨.-**

រាល់គម្រោងអភិវឌ្ឍន៍និងថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ដែលបានទទួលការឯកភាពជាគោលការណ៍ពីរាជរដ្ឋាភិបាល សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់អាចអនុវត្តគម្រោងនេះដោយខ្លួនឯង ឬអនុញ្ញាតឲ្យផ្នែកឯកជនចូលរួមអភិវឌ្ឍនិងថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្របតាមច្បាប់ស្តីពី លទ្ធកម្មសាធារណៈ ។

ក្នុងករណីដែលសម្បទានិក ឬក្រុមហ៊ុនសាងសង់ផ្លូវថ្នល់ជាអ្នកអនុវត្តគម្រោងអភិវឌ្ឍន៍ ឬគម្រោងថែទាំផ្លូវថ្នល់ ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ច្បាប់ស្តីពីសម្បទាន និងបទប្បញ្ញត្តិពាក់ព័ន្ធ

**មាត្រា ១៩.-**

សម្បទានិក ឬក្រុមហ៊ុនសាងសង់ផ្លូវថ្នល់ ត្រូវសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដែលបំពេញតួនាទីក្នុងសមត្ថកិច្ចជាអ្នកគ្រប់គ្រង ត្រួតពិនិត្យ សវនកម្ម ឬដោះស្រាយវិវាទផ្លូវថ្នល់ និងត្រូវផ្តល់របាយការណ៍ទៀងទាត់អំពីការសាងសង់ ការថែទាំផ្លូវថ្នល់ ឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍ និងរបាយ-ការណ៍បន្ទាន់ ក្នុងករណីមានព្រឹត្តិការណ៍អ្វីមួយកើតឡើងពាក់ព័ន្ធ នឹងផ្លូវថ្នល់ ។

## ជំពូកទី ៥
## អង្គភាពបច្ចេកទេស
## និងបទប្បញ្ញត្តិបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់

**មាត្រា ២០.-**

សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ ត្រូវរៀបចំរចនាសម្ព័ន្ធចាត់តាំងរបស់ខ្លួនឲ្យឆ្លើយតបនឹងផែនការអភិវឌ្ឍន៍វិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងតម្រូវការសេវាសាធារណៈ ។

**មាត្រា ២១.-**

សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ ត្រូវរៀបចំឲ្យមានវិទ្យាស្ថានជាតិអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ។ វិទ្យាស្ថាននេះ មានតួនាទីសិក្សា ស្រាវជ្រាវ ពិសោធ និងបណ្តុះបណ្តាល និងជាមណ្ឌលគ្រប់គ្រងប្រមូល និងចែកចាយព័ត៌មានដែលទាក់ទងនឹងវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់វិទ្យាស្ថានជាតិអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ២២.-**

សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ ត្រូវរៀបចំឲ្យមានមន្ទីរពិសោធន៍ថ្នាក់ជាតិវិស័យផ្លូវថ្នល់មួយ ។ មន្ទីរពិសោធន៍នេះ មានតួនាទីធ្វើការពិសោធន៍គុណភាព វាយតម្លៃសម្ភារៈសំណង់ រូបធាតុសម្ភារៈផ្សេងៗ ដែលយកមកប្រើប្រាស់ក្នុងការងារអនុវត្ត និងចេញលិខិតបញ្ជាក់គុណភាពពាក់ព័ន្ធនឹងវិស័យសាធារណការ ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរពិសោធន៍ថ្នាក់ជាតិវិស័យផ្លូវថ្នល់ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ២៣.-**

ក្រសួងសាធារណការ និងដឹកជញ្ជូន មានសមត្ថកិច្ចក្នុងការរៀបចំបទប្បញ្ញត្តិ បច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងការតម្រូវលើបច្ចេកទេសផ្សេងទៀតឲ្យស្របនឹងបទប្បញ្ញត្តិបច្ចេកទេសអន្តរជាតិ ក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ មានដូចខាងក្រោម ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

១- បទប្បញ្ញត្តិបច្ចេកទេសសាងសង់ផ្លូវ សាងសង់ស្ពាន ។

២- បទប្បញ្ញត្តិបច្ចេកទេសបរិក្ខារផ្លូវថ្នល់ បរិក្ខារសម្រួលការបង្ហូរទឹក និងសំណង់សិល្បការ្យ ។

៣- បទប្បញ្ញត្តិបច្ចេកទេសសុវត្ថិភាពនិងការថែទាំគ្រឿងចក្រធុនធ្ងន់ ។

៤- បទប្បញ្ញត្តិបច្ចេកទេសសុវត្ថិភាពការងារសម្រាប់កម្មករសំណង់សាធារណការ ។

៥- បទប្បញ្ញត្តិបច្ចេកទេសនិងនីតិវិធីជួសជុលថែទាំផ្លូវថ្នល់ ។

៦- បទប្បញ្ញត្តិបច្ចេកទេសសាងសង់ស្ថានីយថ្លឹងយានយន្ត ស្ថានីយចំណតរថយន្ត ទីសំចតរថយន្ត ស្ថានីយឈប់សម្រាក ទីតាំងលំហែ នៅតាមបណ្តាញផ្លូវថ្នល់ ។

៧- បទប្បញ្ញត្តិបច្ចេកទេសផ្សេងទៀតដែលបម្រើឲ្យវិស័យសាធារណការផ្នែកហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ។

បទប្បញ្ញត្តិបច្ចេកទេសនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ។

## ជំពូកទី ៦
## ការប្រើប្រាស់ផ្លូវថ្នល់

**មាត្រា ២៤.-**

អ្នកប្រើប្រាស់ផ្លូវថ្នល់និងអ្នកជាប់ពាក់ព័ន្ធនឹងផ្លូវថ្នល់ទាំងអស់ ត្រូវគោរពតាមបទប្បញ្ញត្តិដូចមានចែងក្នុងច្បាប់នេះ និងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

ច្បាប់នេះត្រូវមានអាទិភាព ក្នុងករណីដែលបទប្បញ្ញត្តិនៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកមិនស្របគ្នានឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ២៥.-**

អ្នកប្រើប្រាស់យានយន្តដឹកជញ្ជូនលើផ្លូវថ្នល់ ត្រូវអនុវត្តតាមការកំណត់អំពីការផ្ទុកទម្ងន់ដូចមានចែងក្នុងមាត្រា ២៦ នៃច្បាប់នេះ និងត្រូវចូលត្រួតពិនិត្យថ្លឹងទម្ងន់នៅស្ថានីយថ្លឹងយានយន្តដែលស្ថិតនៅតាមបណ្តាញផ្លូវថ្នល់នីមួយៗ ព្រមទាំងគោរពតាមបទដ្ឋានបច្ចេកទេសទំហំផ្លូវកម្រិតកំណត់ ។

បទដ្ឋានបច្ចេកទេសទំហំផ្លូវកម្រិតកំណត់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូននិងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ។

ការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ជាសមត្ថកិច្ចរបស់គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ២៦.-**

ទម្ងន់ដឹកជញ្ជូនអតិបរមាលើបណ្ដាញផ្លូវថ្នល់ មានដូចតទៅ ៖

១- លើផ្លូវល្បឿនលឿន ផ្លូវជាតិ ផ្លូវខេត្ត ផ្លូវរាជធានី ផ្លូវក្រុង ផ្លូវទីប្រជុំជននានាក្នុងខេត្ត និងផ្លូវជនបទ ត្រូវអនុវត្តដូចខាងក្រោម ៖

**ក- ការកម្រិតទម្ងន់អតិបរមាសង្កត់លើភ្លៅរថយន្ត រ៉ឺម៉ក ឬសឺមីរ៉ឺម៉កត្រូវកំណត់ត្រឹម ៖**

- ៦(ប្រាំមួយ)តោន សម្រាប់ភ្លៅទោលដែលមានកង់២(ពីរ) ស្ថិតនៅផ្នែកចង្កូតរថយន្ត
- ១១(ដប់មួយ)តោន សម្រាប់ភ្លៅភ្លោះដែលមានកង់៤(បួន) ស្ថិតនៅផ្នែកចង្កូតរថយន្ត
- ១០(ដប់)តោន សម្រាប់ភ្លៅទោលដែលមានកង់៤(បួន)
- ១៩(ដប់ប្រាំបួន)តោន សម្រាប់ភ្លៅភ្លោះដែលមានកង់៨(ប្រាំបី)
- ២៤(ម្ភៃបួន)តោន សម្រាប់ភ្លៅបីជិតគ្នាដែលមានកង់១២(ដប់ពីរ) ។

**ខ- ការកម្រិតទម្ងន់សរុបអនុញ្ញាតអតិបរមារបស់រថយន្ត ត្រូវកំណត់ត្រឹម ៖**

- ១៦(ដប់ប្រាំមួយ)តោន សម្រាប់រថយន្តដែលមានភ្លៅ២(ពីរ) គឺភ្លៅទោលផ្នែកខាងមុខរថយន្តដែលមានកង់២(ពីរ)និងភ្លៅទោលផ្នែកខាងក្រោយរថយន្តដែលមានកង់៤(បួន)
- ២៥(ម្ភៃប្រាំ)តោន សម្រាប់រថយន្តដែលមានភ្លៅ៣(បី) គឺភ្លៅទោលផ្នែកខាងមុខរថយន្តដែលមានកង់២(ពីរ) និងភ្លៅភ្លោះផ្នែកខាងក្រោយរថយន្តដែលមានកង់៨(ប្រាំបី)
- ៣០(សាមសិប)តោន សម្រាប់រថយន្តដែលមានភ្លៅ៤(បួន) គឺភ្លៅភ្លោះផ្នែកខាងមុខរថយន្តដែលមានកង់៤(បួន) និងភ្លៅភ្លោះផ្នែកខាងក្រោយរថយន្តដែលមានកង់៨(ប្រាំបី) ។

**គ- ការកម្រិតទម្ងន់សរុបអនុញ្ញាតអតិបរមារបស់រថយន្តសណ្ដោងរ៉ឺម៉កត្រូវកំណត់ត្រឹម ៖**

- ៣៥(សាមសិបប្រាំ)តោន សម្រាប់រថយន្តសណ្ដោងរ៉ឺម៉កដែលមានភ្លៅ៤(បួន) គឺភ្លៅទោលផ្នែកខាងមុខរថយន្តដែលមានកង់២(ពីរ) ភ្លៅទោលផ្នែកខាងក្រោយរថយន្តដែលមានកង់៤(បួន)និងភ្លៅទោលផ្នែកខាងក្រោយរ៉ឺម៉កដែលមានកង់៤(បួន)
- ៤០(សែសិប)តោន សម្រាប់រថយន្តសណ្ដោងរ៉ឺម៉កដែលមានភ្លៅចាប់ពី៥(ប្រាំ) ឡើងទៅ ។

**ឃ-ការកម្រិតទម្ងន់សរុបអនុញ្ញាតអតិបរមា របស់រថយន្តសណ្ដោងសឺមីរ៉ឺម៉កត្រូវកំណត់ត្រឹម ៖**

- ៣៥(សាមសិបប្រាំ)តោន សម្រាប់រថយន្តសណ្ដោងសឺមីរ៉ឺម៉កដែលមានភ្លៅ៤(បួន) គឺភ្លៅទោលផ្នែកខាងមុខរថយន្តដែលមានកង់២(ពីរ) ភ្លៅទោលផ្នែកខាងក្រោយ

រថយន្តដែលមានកង់៤(បួន) និងភ្លៅភ្ជោះផ្នែកខាងក្រោយសឺមីរ៉ឺម៉កដែលមាន
កង់៨(ប្រាំបី)

- ៤០(សែសិប)តោន សម្រាប់រថយន្តសណ្តោងសឺមីរ៉ឺម៉កដែលមានភ្លៅ៥(ប្រាំ) ។

ចំពោះទម្ងន់រថយន្ត និងរថយន្តសណ្តោងរ៉ឺម៉ក ឬសឺមីរ៉ឺម៉ក ដែលគ្មានចែងនៅក្នុងចំណុចខាងលើនេះ ត្រូវសុំលិខិតអនុញ្ញាតពិសេសពីសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ ។

២- រាល់ទម្ងន់សង្កត់លើអ័ក្សភ្លៅរថយន្តដូចមានចែងក្នុងចំណុចទី១ ខាងលើ ត្រូវមានសម្ពាធទៅលើផ្ទៃថ្នល់មិនលើសពី៥(ប្រាំ)គក្រ/សម$^{២}$ ។

**មាត្រា ២៧.-**

អ្នកប្រើប្រាស់ផ្លូវថ្នល់ក្នុងពេលទៅដល់កំពង់ចម្លង ឬផ្លូវឡើងចំណោតខ្ពស់ ឬផ្លូវតម្រូវឲ្យមានការប្រុងប្រយ័ត្នខ្ពស់ ត្រូវគោរពតាមការបញ្ជារបស់ភ្នាក់ងារកំពង់ចម្លង ឬភ្នាក់ងារសុវត្ថិភាពដែលប្រចាំការនៅតាមគោលដៅ ។

បទបញ្ជានៃការប្រើប្រាស់កំពង់ចម្លងនិងការប្រើប្រាស់ផ្លូវឡើងចំណោតខ្ពស់ ឬផ្លូវតម្រូវឲ្យមានការប្រុងប្រយ័ត្នខ្ពស់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូននិងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ។

**មាត្រា ២៨.-**

ការរៀបចំចាត់ចែងសកម្មភាពនានាដូចជា សកម្មភាពវប្បធម៌ កីឡា ការតាំងពិព័រណ៍ និងពិធីបុណ្យផ្សេងទៀតនៅលើដងផ្លូវថ្នល់ ត្រូវប្រតិបត្តិតាមការណែនាំដូចខាងក្រោម ៖

១- អ្នករៀបចំត្រូវលើកសំណើសុំប្រើប្រាស់ផ្លូវថ្នល់ ដោយភ្ជាប់ជាមួយនូវគម្រោងការពារសុវត្ថិភាពចរាចរណ៍ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។ សកម្មភាពនេះអាចប្រព្រឹត្តទៅបានក្រោយពេលទទួលបានការអនុញ្ញាតពីរដ្ឋបាលថ្នាក់ក្រោមជាតិតាមលំដាប់ថ្នាក់ទៅតាមកម្រិត នៃពិធី និងតាមភាពចាំបាច់ ។

២- រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវផ្សព្វផ្សាយព័ត៌មានអំពីគម្រោងបិទផ្លូវថ្នល់ឲ្យបានទាន់ពេលវេលាព្រមទាំងចាត់វិធានការការពារសណ្តាប់ធ្នាប់ និងសុវត្ថិភាពចរាចរណ៍ឲ្យបានត្រឹមត្រូវ ។

៣- រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវចូលរួមសហការជាមួយអ្នករៀបចំ ដើម្បីធ្វើការចាត់ចែងកិច្ចការបន្ទាន់ និងធានាសុវត្ថិភាពចរាចរណ៍ ។

បែបបទ និងនីតិវិធីនៃការប្រើប្រាស់ផ្លូវថ្នល់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ឬប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ។

**មាត្រា ២៩.-**

ការប្រើប្រាស់ផ្លូវថ្នល់និងសកម្មភាពផ្សេងៗ ពាក់ព័ន្ធនឹងផ្លូវថ្នល់តាមដងផ្លូវនៅក្នុងរាជធានី ក្រុង និងទីប្រជុំជន ត្រូវអនុវត្តដូចតទៅ ៖

ក- ចិញ្ចើមផ្លូវនិងផ្លូវថ្មើរជើងត្រូវប្រើប្រាស់សម្រាប់តែគោលបំណង ក្នុងការធ្វើចរាចរណ៍ដោយថ្មើរជើង ។

ខ- ចិញ្ចើមផ្លូវនិងផ្លូវថ្មើរជើងអាចយកទៅប្រើប្រាស់សម្រាប់គោលបំណងផ្សេងទៀតបានស្របតាមបញ្ញត្តិនៃមាត្រា ២៨ នៃច្បាប់នេះ ។

គ- មិនត្រូវអនុវត្តសកម្មភាពដូចខាងក្រោម ៖

- ចតរថយន្ត ឬយានជំនិះមិនត្រឹមត្រូវ តាមដងផ្លូវ ចិញ្ចើមផ្លូវ និងផ្លូវសម្រាប់ថ្មើរជើងខុសពីទីតាំងកំណត់
- សាងសង់របារកាត់ទទឹង ឬទួលបន្ថយល្បឿន ឬវត្ថុប្រហាក់ប្រហែលពីលើផ្លូវថ្នល់ដោយគ្មានការអនុញ្ញាត
- ធ្វើសកម្មភាពផ្សេងទៀតផ្ទុយពីច្បាប់នេះ ។

**មាត្រា ៣០.-**

ដើម្បីធានាដល់ការធ្វើចរាចរណ៍លើផ្លូវល្បឿនលឿន ផ្លូវជាតិ ផ្លូវខេត្ត ប្រកបដោយសុវត្ថិភាព រាល់ការសាងសង់សំណង់ដែលមានច្រកផ្លូវចេញចូលជាប់នឹងផ្លូវថ្នល់ខាងលើនេះ ត្រូវអនុវត្តដូចខាងក្រោម ៖

១- ការសាងសង់សំណង់ដូចជា ស្ថានីយប្រេងឥន្ធនៈ ស្ថានីយហ្គាស កន្លែងលាងយានយន្ត យានដ្ឋាន ឬសំណង់ប្រហាក់ប្រហែលផ្សេងៗទៀត ដែលមានមនុស្សជួបជុំគ្នាមធ្យមត្រូវស្ថិតក្នុងចម្ងាយយ៉ាងតិច ១៥(ដប់ប្រាំ)ម៉ែត្រ ពីខ្សែបន្ទាត់ព្រំដីចំណីផ្លូវ ។

២- ការសាងសង់មជ្ឈមណ្ឌលពាណិជ្ជកម្ម ពហុកីឡដ្ឋាន ទីលានប្រកួត រោងមហោស្រពមន្ទីរពេទ្យ គ្រឹះស្ថានសិក្សា ការរៀបចំផ្សារ ផ្សារណាត់ ពិព័រណ៍ទំនិញ ឬកិច្ចការផ្សេងទៀតដែលមានមនុស្សជួបជុំគ្នាច្រើន ត្រូវស្ថិតក្នុងចម្ងាយយ៉ាងតិចបំផុត៥០(ហាសិប)ម៉ែត្រ ពីខ្សែបន្ទាត់ព្រំដីចំណីផ្លូវថ្នល់ ។

៣- ការកំណត់ដូចមានចែងក្នុងចំណុចទី១ និងទី២ ខាងលើនេះ មិនអនុវត្តចំពោះរាល់សំណង់ដែលបានសាងសង់ពីមុនស្របតាមបទប្បញ្ញត្តិជាធរមានឡើយ ។

៤- ការកំណត់ចម្ងាយដូចមានចែងនៅចំណុចទី១ និងទី២ ខាងលើចំពោះផ្លូវជនបទត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ៣១.-**

អ្នកធ្វើកិច្ចការសាធារណការដូចជា ការបោះបង្គោលខ្សែភ្លើង ការដាក់លូ ឬកិច្ចការចាំបាច់អ្វីមួយបន្ថែមក្នុង តួផ្លូវ ទ្រូងផ្លូវ ជាយផ្លូវ គែមផ្លូវ និងដីនៅសល់នៃដីចំណីផ្លូវ ត្រូវស្នើសុំការអនុញ្ញាតពីសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ ។

**មាត្រា ៣២.-**

ការជីកកប់ ការជីកគាស់ ការបោះខួង ឬសកម្មភាពផ្សេងទៀតសម្រាប់បម្រើការងារអាជីវកម្ម ដែលអាចបង្កឲ្យខូចខាតនិងប៉ះពាល់តួផ្លូវ ទ្រូងផ្លូវ ជាយ ឬចិញ្ចើមផ្លូវ ដីចំណីផ្លូវ និងការដំឡើងផ្ទាំងផ្សាយពាណិជ្ជកម្ម ឬការលើកតាំងបង្ហាញប៉ាណូផ្សេងៗ នៅតាមដងផ្លូវថ្នល់ ឬដីចំណីផ្លូវ ត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ ។ អ្នកអនុវត្តការងារ ត្រូវចាត់វិធានការសណ្តាប់ធ្នាប់ សម្រួលចរាចរណ៍ ការពារនឹងឧបទ្ទវហេតុផ្សេងៗដែលកើតមានឡើងដោយថាហេតុ ការពារបរិស្ថានឲ្យបានត្រឹមត្រូវ និងត្រូវគោរពតាមការណែនាំរបស់សមត្ថកិច្ចជំនាញ ។

អ្នកអនុវត្តការងារដូចមានចែងក្នុងកថាខណ្ឌខាងលើ បន្ទាប់ពីបញ្ចប់ការងាររបស់ខ្លួន ត្រូវជានាប្រក្រតីភាពផ្លូវថ្នល់ឲ្យមានស្ថានភាពដូចដើមវិញ ។

**មាត្រា ៣៣.-**

រាល់សកម្មភាពដូចមានចែងក្នុងមាត្រា ៣២ នៃច្បាប់នេះ ត្រូវបង់កម្រៃជូនសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ ។ ករណីនេះអាចលើកលែងបាន ប្រសិនបើសកម្មភាពទាំងនោះប្រព្រឹត្តទៅក្នុងគោលបំណងបម្រើឲ្យផលប្រយោជន៍សាធារណៈ ដោយមានការអនុញ្ញាតពីរាជរដ្ឋាភិបាល ។

កម្រៃដូចមានចែងក្នុងកថាខណ្ឌខាងលើ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ឬប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ សម្រាប់ជាប្រយោជន៍ថវិកាជាតិ ។

**មាត្រា ៣៤.-**

សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់អាចបើកច្រកផ្លូវចេញចូល ឬបង្វែរទិសផ្លូវ ឬបិទផ្លូវទាំងស្រុង ឬបិទចំណែកណាមួយឲ្យ ឬមិនឲ្យធ្វើចរាចរណ៍ជាបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ ក្រោយពេលទទួលបានការឯកភាពពីរាជរដ្ឋាភិបាល និងត្រូវជូនដំណឹងជាសាធារណៈ ។

ការសម្រេចដូចមានចែងក្នុងកថាខណ្ឌខាងលើ អាចធ្វើទៅបានក្នុងករណីដូចខាងក្រោម ៖

១- ការពារទ្រព្យសម្បត្តិបេតិកភណ្ឌជាតិ ។

២- បម្រើផលប្រយោជន៍សុវត្ថិភាពចរាចរណ៍សាធារណៈ ។

៣- មានប្រធានសក្តិ ។

ក្នុងករណីទាំង៣ ខាងលើនេះ សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ត្រូវ ៖

- កំណត់ឲ្យប្រើប្រាស់ផ្លូវថ្នល់ផ្សេងដែលមានស្រាប់ជំនួសវិញ
- ក្នុងករណីគ្មានផ្លូវផ្សេងជំនួស ត្រូវដោះស្រាយ កែសម្រួល ឬរៀបចំឲ្យមានផ្លូវថ្មីសម្រាប់ជំនួសផ្លូវដែលបានបិទ ឬបង្វែរទិសនោះ ។

ចំពោះការបិទ ការបើក ឬការបង្វែរផ្លូវថ្នល់ធ្វើចរាចរណ៍ជាបណ្ដោះអាសន្ន ក្នុងរយៈពេលខ្លី សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ អាចធ្វើសេចក្តីជូនដំណឹងជាសាធារណៈជាបន្ទាន់ ។

## ជំពូកទី ៧
## ការការពារហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់

**មាត្រា ៣៥.-**

អ្នកគ្រប់គ្រងអចលនវត្ថុនៅក្បែរផ្លូវថ្នល់ មិនត្រូវធ្វើឲ្យរាំងស្ទះការធ្វើចរាចរណ៍ ឬធ្វើឲ្យខូចខាតផ្លូវថ្នល់ ។ ក្នុងករណីមានបញ្ហាកើតឡើងដោយសារសកម្មភាពទាំងនោះ សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកគ្រប់គ្រងអចលនវត្ថុ ដើម្បីចាត់ចែងកែសម្រួលឧបសគ្គទាំងនោះក្នុងរយៈពេលមួយសមស្រប ។ ក្នុងករណីដែលអ្នកគ្រប់គ្រងអចលនវត្ថុបានទទួលដំណឹងហើយមិនព្រមអនុវត្ត សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់មានសិទ្ធិរុះរើយកចេញដោយគ្មានការទាមទារអ្វីឡើយ ហើយអ្នកគ្រប់គ្រងអចលនវត្ថុនោះជាអ្នកទទួលខុសត្រូវលើការចំណាយក្នុងកិច្ចការរុះរើផងដែរ ។

**មាត្រា ៣៦.-**

បុគ្គលដែលមានបំណងចាក់ដី ឬធ្វើអ្វីមួយលើដីចំណីផ្លូវ សម្រាប់ធ្វើផ្លូវចេញចូលគេហដ្ឋាន ក្រុមហ៊ុន រោងចក្រ សហគ្រាស ឬកន្លែងផ្សេងៗជាប់ផ្លូវថ្នល់ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតជាលាយលក្ខណ៍អក្សរទៅសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ ឬអ្នកគ្រប់គ្រងផ្លូវថ្នល់ ហើយអាចអនុវត្តការងាររបស់ខ្លួនបានក្រោយពេលទទួលបានលិខិតអនុញ្ញាតជាផ្លូវការ និងត្រូវគោរពតាមការណែនាំរបស់សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ ឬអ្នកគ្រប់គ្រងផ្លូវថ្នល់ ។

ទម្រង់ បែបបទ និងនីតិវិធីនៃការស្នើសុំការអនុញ្ញាត ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ។

**មាត្រា ៣៧.-**

សមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ត្រូវចាត់វិធានការតាមផ្លូវច្បាប់ទប់ស្កាត់រាល់ការបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងការរំលោភលើដីចំណីផ្លូវ ។

បុគ្គលដែលបានឃើញហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ខូចខាត បែកបាក់ ឬបាក់ស្រុត ត្រូវប្រញាប់រាយការណ៍ជូនសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ឬស្ថាប័នមានសមត្ថកិច្ចនៅកន្លែងជិតបំផុតដើម្បីចាត់វិធានការ ។

**មាត្រា ៣៨.-**

ហាមឃាត់រាល់សកម្មភាពបង្កអន្តរាយដល់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងបង្កើតឧបសគ្គដល់សុវត្ថិភាពចរាចរណ៍ដូចជា ៖

**១- ការបំផ្លិចបំផ្លាញដោយចេតនាលើសមាសភាពហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ៖**

- ការជីកគាស់ ការចោះខួង ការធ្វើឱ្យបែកបាក់ផ្លូវថ្នល់
- ការនាំចូលយានយន្ត យានូបករណ៍
- ការទន្ទ្រាន ឬការចូលត្រួតត្រា ឬការប្រើប្រាស់ដីរបស់ផ្លូវថ្នល់ និងពិសេសដីចំណីផ្លូវ
- ការកែប្រែ ឬបង្វែរផ្លូវថ្នល់ដោយគ្មានការអនុញ្ញាត
- ការសាងសង់ក្នុងដីចំណីផ្លូវ លុបគន្លងបង្ហូរទឹកសម្រួលសុវត្ថិភាពផ្លូវថ្នល់ ។

**២- ការបង្កើតឧបសគ្គរារាំង ដែលនាំឱ្យរំខានដល់សុវត្ថិភាពចរាចរណ៍ ៖**

- ការធ្វើផ្ទៃផ្លូវថ្នល់រអិល ស្អិត និងការធ្វើឱ្យទ្រេត ឬដួលរលំបរិក្ខារផ្លូវថ្នល់
- ការផ្លាស់ប្តូរ ការសរសេរ ការរុះរើចល័ត ការដោះយក ឬការធ្វើឱ្យខូចប្រយោជន៍ដល់ផ្លាកសញ្ញាចរាចរណ៍ ភ្លើងសញ្ញាចរាចរណ៍ របងការពារសុវត្ថិភាព បង្គោលគីឡូម៉ែត្រ សញ្ញាបង្ហាញទិស និងការបង្កើតឧបសគ្គរាំងនៅលើផ្លូវថ្នល់
- ការចាក់គំនរកម្ទេចសំណង់ពង្រាយលើផ្លូវថ្នល់ ឬការដាក់គរសម្ភារៈវត្ថុរាយប៉ាយលើផ្លូវថ្នល់ជាអាទិ៍ ការបោះចោលកម្ទេចកម្ទីថ្ម អាចម៍ដី ខ្សាច់ សំរាម ទឹកកខ្វក់ កាកសំណល់ និងការហាលវត្ថុផ្សេងទៀតនៅលើផ្លូវថ្នល់ ក្នុងករណីមានកន្លែងផ្សេងទៀត សម្រាប់ហាល ។

**៣- សកម្មភាពដែលអាចបណ្តាលឱ្យមានឧបសគ្គដល់ការធ្វើចរាចរណ៍ ៖**

- ការរៀបចំពិធីផ្សេងៗបំពានលើផ្លូវថ្នល់ជាអាទិ៍ ផ្សារណាត់ ការរាំរែក ការលក់ទំនិញលើផ្លូវថ្នល់ និងការជួបជុំមហាជន ការយកផ្លូវថ្នល់ ស្ពានធ្វើជាកន្លែងស្នាក់នៅផ្ទុយពីច្បាប់នេះ

- ការដាក់តាំងសម្ភារៈ ឬផ្លាកសញ្ញាផ្សេងៗធ្វើឲ្យបាំងភ្នែក ឬកាត់បន្ថយការប្រុងប្រយ័ត្ន អ្នកបើកបរ ឬបង្កឧបសគ្គដល់អ្នកថ្មើរជើងធ្វើដំណើរ
- ការសាងសង់ជញ្ជាំងបាំងលយចេញ ឬសំណង់អ្វីមួយលើគែមផ្លូវថ្នល់ ចិញ្ចើមផ្លូវថ្នល់
- ការចាក់ដីខ្ពស់ជាងផ្លូវថ្នល់ ដោយមិនមានប្រព័ន្ធបង្ហូរទឹកត្រឹមត្រូវ
- ការលើកផ្លូវ ឬការបើកផ្លូវតភ្ជាប់ទៅផ្លូវធំដោយគ្មានច្បាប់អនុញ្ញាត ។

៤- រាល់សកម្មភាពផ្សេងៗទៀត ដែលធ្វើឲ្យអន្តរាយផ្លូវថ្នល់ បង្កឲ្យមានគ្រោះថ្នាក់ដល់មនុស្ស និងមធ្យោបាយធ្វើដំណើរនៅលើផ្លូវថ្នល់ ។

## ជំពូកទី ៨
## អាជ្ញាបណ្ណផ្លូវថ្នល់

**មាត្រា ៣៩.-**

ការប្រកបអាជីវកម្មលើវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ការថែទាំ និងការបើកមន្ទីរពិសោធន៍វិស័យផ្លូវថ្នល់ ត្រូវមានអាជ្ញាបណ្ណ ។

លក្ខខណ្ឌនិងនីតិវិធីនៃការស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មលើវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ការថែទាំផ្លូវថ្នល់ និងការបើកមន្ទីរពិសោធវិស័យផ្លូវថ្នល់ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៤០.-**

ការស្នើសុំអាជ្ញាបណ្ណលើវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ការថែទាំផ្លូវថ្នល់ និងការបើកមន្ទីរពិសោធន៍ពាក់ព័ន្ធនឹងវិស័យផ្លូវថ្នល់ ត្រូវបង់កម្រៃអាជ្ញាបណ្ណ ។

កម្រៃអាជ្ញាបណ្ណ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ឬប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងត្រូវបានជាប្រយោជន៍ដល់ថវិកាជាតិ ។

## ជំពូកទី ៩
## ថវិកាសម្រាប់អភិវឌ្ឍន៍និងថែទាំផ្លូវថ្នល់

**មាត្រា ៤១.-**

នៅរាល់ដំណាច់ឆ្នាំនីមួយៗ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំគម្រោងថវិកាសម្រាប់អភិវឌ្ឍ និងថែទាំផ្លូវថ្នល់ក្នុងក្របខ័ណ្ឌកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ខ្លួន ។

**មាត្រា ៤២.-**

ថវិកាសម្រាប់អភិវឌ្ឍនិងថែទាំផ្លូវថ្នល់ ត្រូវស្ថិតក្រោមច្បាប់ស្តីពីហិរញ្ញវត្ថុ ហើយមានប្រភព

ធនធានមកពី ៖

- ថវិកាជាតិ
- ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍនានា
- ហិរញ្ញប្បទានពីវិស័យឯកជន
- អំណោយសប្បុរសធម៌ពីសប្បុរសជន អង្គការជាតិ អន្តរជាតិ សមាគម ឬសហគមន៍
- ផលចំណេញពីការវិនិយោគ និងអាជីវកម្មស្របច្បាប់លើវិស័យផ្លូវថ្នល់
- ប្រាក់ពិន័យអន្តរការណ៍
- ចំណូលពីប្រភពស្របច្បាប់ផ្សេងទៀត ។

## ជំពូកទី ១០
## អធិការកិច្ចផ្លូវថ្នល់

**មាត្រា ៤៣.-**

សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ មានសិទ្ធិចាត់តាំងមន្ត្រីអធិការកិច្ចផ្លូវថ្នល់ដើម្បីតាមដានស្រាវជ្រាវ ត្រួតពិនិត្យ និងជំរុញការអនុវត្តច្បាប់ ។

មន្ត្រីអធិការកិច្ចផ្លូវថ្នល់ ទទួលនីតិសម្បទាឲ្យពិនិត្យបទល្មើសដូចមានចែងក្នុងច្បាប់នេះស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បែបបទ និងនីតិវិធីនៃការផ្តល់នីតិសម្បទាចំពោះមន្ត្រីអធិការកិច្ចផ្លូវថ្នល់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ឬប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ។

**មាត្រា ៤៤.-**

មន្ត្រីអធិការកិច្ចផ្លូវថ្នល់ មានសិទ្ធិស្នើសុំជំនួយសហការពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីចូលរួមបង្ក្រាបបទល្មើសដូចមានចែងក្នុងច្បាប់នេះ ។

**មាត្រា ៤៥.-**

ក្នុងពេលប្រតិបត្តិការអនុវត្តច្បាប់ មន្ត្រីអធិការកិច្ចផ្លូវថ្នល់ត្រូវស្លៀកពាក់ឯកសណ្ឋាន និងមានបណ្ណសម្គាល់ខ្លួន ព្រមទាំងមានលិខិតអនុញ្ញាតឲ្យបំពេញបេសកកម្ម ។

ឯកសណ្ឋាននិងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៤៦.-**

មន្ត្រីអធិការកិច្ចផ្លូវថ្នល់ មានសិទ្ធិធ្វើអធិការកិច្ចនិងចាត់វិធានការដូចខាងក្រោម ៖

- ធ្វើសវនកម្មនិងធ្វើការត្រួតពិនិត្យជាប្រចាំទៅលើសមាសភាពហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងមន្ទីរពិសោធន៍ឯកជនដែលប្រកបអាជីវកម្មលើវិស័យផ្លូវថ្នល់

- ទទួលសិទ្ធិ និងទទួលសំណៅឯកសារផ្សេងៗពីប្រភពផ្តល់ និងទីតាំងផលិតសម្ភារៈផ្សេងៗ ដែលបម្រើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ក្នុងលក្ខខណ្ឌបុរេនិច្ឆ័យការងារសាងសង់ និងបរិស្ថាន ដែលអាចបង្កមហន្តរាយ និងផលប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់
- ត្រួតពិនិត្យ បញ្ឈប់ និងពិន័យអន្តរការណ៍ លើរាល់មហន្តរាយ និងផលប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់
- ដកហូតជាបណ្តោះអាសន្ននូវលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាក់ព័ន្ធ ក្នុងករណីដែលអ្នកកាន់កាប់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណនោះប្រព្រឹត្តល្មើសនឹងច្បាប់នេះ ។

នីតិវិធីនៃការធ្វើអធិការកិច្ចផ្លូវថ្នល់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ។

**មាត្រា ៤៧.-**

បុគ្គលណាដែលមិនសុខចិត្តចំពោះវិធានការណាមួយ របស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់មានសមត្ថកិច្ច អាចធ្វើបណ្តឹងតវ៉ាក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការងារទៅស្ថាប័នមានសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេច ។

រដ្ឋមន្ត្រីប្រធានស្ថាប័ន ត្រូវសម្រេចបណ្តឹងតវ៉ាក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃនៃថ្ងៃធ្វើការងារយ៉ាងយូរ គិតពីថ្ងៃទទួលពាក្យប្តឹង ។

ក្នុងករណីដែលបុគ្គលណាមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីប្រធានស្ថាប័ន បុគ្គលនោះមានសិទ្ធិធ្វើបណ្តឹងទៅយន្តការផ្សេងទៀតរបស់រាជរដ្ឋាភិបាល ឬទៅតុលាការតាមនីតិវិធី ។

## ជំពូកទី ១១
## ទោសប្បញ្ញត្តិ

**មាត្រា ៤៨.-**

ទណ្ឌកម្មក្នុងបទល្មើសនៃច្បាប់នេះរួមមាន ការព្រមានជាលាយលក្ខណ៍អក្សរ ការដកហូត ឬការព្យួរវិញ្ញាបនបត្រ អាជ្ញាបណ្ណ ការពិន័យអន្តរការណ៍ ទោសពិន័យជាប្រាក់ និងទោសដាក់ពន្ធនាគារ ។

**មាត្រា ៤៩.-**

ការព្រមានជាលាយលក្ខណ៍អក្សរ ការដកហូតឬការព្យួរវិញ្ញាបនបត្រ និងអាជ្ញាបណ្ណជាសមត្ថកិច្ចរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ ។

ការពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់មន្ត្រីអធិការកិច្ចនៅក្នុងព្រំប្រទល់ដែនដី នៃអង្គភាពដែលខ្លួនត្រូវបានចាត់តាំងឲ្យទៅបម្រើការងារ ។

**មាត្រា ៥០.-**

មន្ត្រីអធិការកិច្ចមានសិទ្ធិពិន័យអន្តរការណ៍លើបទល្មើសដូចមានចែងក្នុងមាត្រា ៥២ ដល់មាត្រា ៧០ នៃច្បាប់នេះ ។

ការពិន័យអន្តរការណ៍អាចអនុវត្តបានក្នុងករណីដែលជនល្មើសសារភាពកំហុស និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍ស្របតាមទោសប្បញ្ញត្តិនៃច្បាប់នេះ ។ ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឲ្យរំលត់បណ្តឹងអាជ្ញា ។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ មន្ត្រីអធិការកិច្ចមានសមត្ថកិច្ច ត្រូវចងក្រងសំណុំរឿងនៃបទល្មើស ហើយបញ្ជូនទៅតុលាការតាមនីតិវិធី ។

ក្នុងករណីដែលមិនស្គាល់អត្តសញ្ញាណរបស់ជនល្មើស មន្ត្រីអធិការកិច្ចត្រូវស្នើសុំព្រះរាជអាជ្ញាមានសមត្ថកិច្ចដើម្បីរឹបអូសវត្ថុតាងនៃបទល្មើសជាសម្បត្តិរដ្ឋ ។ ជនដែលមានប្រយោជន៍ពាក់ព័ន្ធមានសិទ្ធិប្តឹងតវ៉ាចំពោះសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាទៅតុលាការរដ្ឋប្បវេណី ។

នីតិវិធីនៃការពិន័យអន្តរការណ៍លើបទល្មើសដូចមានចែងក្នុងច្បាប់នេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ឬប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ។

**មាត្រា ៥១.-**

ប្រាក់ពិន័យអន្តរការណ៍ ប្រាក់ពិន័យតាមសាលក្រម ឬសាលដីការបស់តុលាការ ឬប្រាក់បានមកពីការលក់វត្ថុតាង ដែលតុលាការសម្រេចរឹបអូសជាសម្បត្តិរដ្ឋត្រូវបង់ចូលថវិកាជាតិ ។

រាជរដ្ឋាភិបាលអាចសម្រេចផ្តល់រង្វាន់លើកទឹកចិត្តដល់មន្ត្រីដែលបានចូលរួមក្នុងករណីបង្ក្រាបបទល្មើសជាក់លាក់ដែលបង្កមហន្តរាយធ្ងន់ធ្ងរដល់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ។

**មាត្រា ៥២.-**

ជនណាដែលទទួលសិទ្ធិសាងសង់ ឬអភិវឌ្ឍន៍ផ្លូវថ្នល់ថ្មី ដែល ៖

១- មិនបានបំពាក់បរិក្ខារផ្លូវថ្នល់តាមគម្រោងប្លង់សាងសង់ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ៥ ០០០ ០០០(ប្រាំលាន)រៀល និងតម្រូវឲ្យបំពាក់ បរិក្ខារផ្លូវថ្នល់ឡើងវិញទាំងអស់ស្របតាមគម្រោងប្លង់សាងសង់ដែលបានកំណត់ក្នុងកិច្ចសន្យា ។

២- បំពាក់បរិក្ខារផ្លូវថ្នល់មិនគ្រប់គ្រាន់តាមគម្រោងប្លង់សាងសង់ និងមិនស្របតាមបទប្បញ្ញត្តិបច្ចេកទេស ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ២ ០០០ ០០០(ពីរលាន)រៀល និងតម្រូវឲ្យបំពាក់បរិក្ខារផ្លូវថ្នល់ឡើងវិញទាំងអស់ ស្របតាមគម្រោងប្លង់សាងសង់ដែលបានកំណត់ក្នុងកិច្ចសន្យា ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

៣- បំពាក់បរិក្ខារផ្លូវថ្នល់គ្រប់គ្រាន់តាមគម្រោងប្លង់សាងសង់ ប៉ុន្តែមិនស្របតាមបទប្បញ្ញត្តិបច្ចេកទេស ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ១ ០០០ ០០០(មួយលាន)រៀល និងតម្រូវឲ្យបំពាក់បរិក្ខារផ្លូវថ្នល់ឡើងវិញទាំងអស់ ស្របតាមគម្រោងប្លង់សាងសង់ដែលបានកំណត់ក្នុងកិច្ចសន្យា ។

**មាត្រា ៥៣.-**

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៥២ ខាងលើនេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសតាមករណីដូចខាងក្រោម ៖

១- ករណីល្មើសនឹងចំណុចទី១ នៃមាត្រា ៥២ ខាងលើនេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ១០ ០០០ ០០០(ដប់លាន)រៀល ។

២- ករណីល្មើសនឹងចំណុចទី២ នៃមាត្រា ៥២ ខាងលើនេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ៥ ០០០ ០០០ (ប្រាំលាន)រៀល ។

៣- ករណីល្មើសនឹងចំណុចទី៣ នៃមាត្រា ៥២ ខាងលើនេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ២ ០០០ ០០០ (ពីរលាន)រៀល ។

**មាត្រា ៥៤.-**

ជនណាដែលទទួលសិទ្ធិសាងសង់ផ្លូវថ្នល់ ផ្លូវប្រសព្វ ផ្លូវប្រសព្វក្នុងលំហ ផ្លូវជាន់គ្នាស្ពានអាកាស ស្ពានរំលង ផ្លូវរូងក្រោមដី ផ្លូវក្រោមទឹក ឬផ្លូវជួបគ្នារវាងផ្លូវថ្នល់ និងផ្លូវអយស្ម័យយាន ដោយមិនគោរពតាមបទប្បញ្ញត្តិបច្ចេកទេសដែលបានកំណត់ក្នុងគម្រោងប្លង់សាងសង់ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ៥ ០០០ ០០០(ប្រាំលាន)រៀល និងត្រូវតម្រូវឲ្យសាងសង់ឡើងវិញតាមគម្រោងប្លង់ដែលបានកំណត់ ។

**មាត្រា ៥៥.-**

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៥៤ ខាងលើនេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ចំនួន ១០ ០០០ ០០០(ដប់លាន)រៀល និងតម្រូវឲ្យសាងសង់ឡើងវិញតាមគម្រោងប្លង់ដែលបានកំណត់ ។

**មាត្រា ៥៦.-**

ជនណាដែលទទួលបានសិទ្ធិអនុវត្តគម្រោងអភិវឌ្ឍន៍ ឬគម្រោងថែទាំផ្លូវថ្នល់ដែល ៖

១- យកថ្លៃប្រើប្រាស់ផ្លូវថ្នល់ ដោយគ្មានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ៥ ០០០ ០០០ (ប្រាំលាន)រៀល ។ ក្នុងករណីដែលទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយនៅតែបន្តប្រព្រឹត្តល្មើសទៀតត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង ។

២- មិនបានផ្សព្វផ្សាយជាសាធារណៈនូវថ្លៃប្រើប្រាស់ផ្លូវថ្នល់ ដែលទទួលបានការឯកភាពពីស្ថាប័នមានសមត្ថកិច្ចតាមការកំណត់ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ២ ០០០ ០០០ (ពីរលាន)រៀល ហើយត្រូវឲ្យធ្វើការផ្សព្វផ្សាយឡើងវិញ ។ ក្នុងករណីដែលទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តល្មើសទៀតត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង ។

៣- មិនព្រមបញ្ចុះថ្លៃប្រើប្រាស់ផ្លូវថ្នល់ នៅពេលមានកិច្ចព្រមព្រៀងជាមួយស្ថាប័នមាន សមត្ថកិច្ចអំពីការបញ្ចុះថ្លៃប្រើប្រាស់ផ្លូវថ្នល់រួចរាល់ហើយ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ២ ០០០ ០០០(ពីរលាន)រៀល ។ ក្នុងករណីដែលទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅប្រព្រឹត្តល្មើសទៀត ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង ។

**មាត្រា ៥៧.-**

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែល មានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៥៦ ខាងលើនេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសតាមករណីដូចខាងក្រោម ៖

១- ករណីល្មើសនឹងចំណុចទី១នៃមាត្រា៥៦ ខាងលើនេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ១០ ០០០ ០០០(ដប់លាន)រៀល ។

២- ករណីល្មើសនឹងចំណុចទី២ នៃមាត្រា៥៦ ខាងលើនេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ៥ ០០០ ០០០(ប្រាំលាន)រៀល ។

៣- ករណីល្មើសនឹងចំណុចទី៣ នៃមាត្រា៥៦ ខាងលើនេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ៥ ០០០ ០០០(ប្រាំលាន)រៀល ។

ក្នុងករណីដែលទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តល្មើសទៀតត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង ។

**មាត្រា ៥៨.-**

សម្បទានិក ឬក្រុមហ៊ុនសាងសង់ផ្លូវថ្នល់ដែលមិនសហការ ឬរារាំងមន្ត្រីមានសមត្ថកិច្ចដែលបំពេញតួនាទីដូចមានចែងក្នុងមាត្រា១៩ នៃច្បាប់នេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ២ ០០០ ០០០ (ពីរលាន)រៀល ។

ក្នុងករណីដែលទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តល្មើស ទៀតត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង ។

**មាត្រា ៥៩.-**

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៥៨ ខាងលើនេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ចំនួន ៥ ០០០ ០០០(ប្រាំលាន)រៀល ។ ក្នុងករណីដែលទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តល្មើសទៀតត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង ។

**មាត្រា ៦០.-**

អ្នកប្រើប្រាស់យានយន្តដឹកជញ្ជូនធុនធ្ងន់ដែលដឹកជញ្ជូនទំនិញលើផ្លូវថ្នល់ដែល ៖

១- មិនចូលថ្លឹងនៅស្ថានីយជញ្ជីងតាមបណ្តាញផ្លូវ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ៥០០ ០០០(ប្រាំសែន) រៀល ។

២- ផ្ទុកទម្ងន់មិនលើស៥ (ប្រាំ)ភាគរយ នៃទម្ងន់កម្រិតកំណត់ត្រូវធ្វើការព្រមានជាលាយលក្ខណ៍អក្សរ ។

៣- ផ្ទុកទម្ងន់លើសពី ៥(ប្រាំ)ភាគរយ ទៅ ១០ (ដប់)ភាគរយ នៃទម្ងន់កម្រិតកំណត់ត្រូវ ៖

ក- រើទំនិញចេញនិងឃាត់យានជំនិះទុកចំនួន ១០ (ដប់)ថ្ងៃ និងត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ១០០ ០០០ (មួយសែន) រៀល ក្នុងទម្ងន់១ (មួយ) តោន ។

ខ- ដកបណ្ណបើកបរ និងព្យួរទុកចំនួន ១០(ដប់) ថ្ងៃ ។

៤- ផ្ទុកទម្ងន់លើសពី១០(ដប់)ភាគរយ ទៅ ២០(ម្ភៃ)ភាគរយ នៃទម្ងន់កម្រិតកំណត់ត្រូវ ៖

ក- រើទំនិញចេញនិងឃាត់យានជំនិះទុកចំនួន ១(មួយ)ខែ និងពិន័យអន្តរការណ៍ជាប្រាក់ចំនួន ២០០ ០០០(ពីរសែន)រៀល ក្នុងទម្ងន់១(មួយ)តោន ។

ខ- ដកបណ្ណបើកបរ និងព្យួរទុកចំនួន ៦(ប្រាំមួយ)ខែ ។

៥- ផ្ទុកទម្ងន់លើសពី២០(ម្ភៃ)ភាគរយ នៃទម្ងន់កម្រិតកំណត់ត្រូវ ៖

ក- រើទំនិញចេញនិងឃាត់យានជំនិះទុកចំនួន ១(មួយ)ឆ្នាំ និងពិន័យអន្តរការណ៍ជាប្រាក់ចំនួន ៣០០ ០០០(បីសែន)រៀល ក្នុងទម្ងន់១(មួយ)តោន ។

ខ- ដកបណ្ណបើកបរ និងព្យួរទុកចំនួន ២(ពីរ)ឆ្នាំ ។

ក្នុងករណីមានអំពើល្មើសលើការផ្ទុកទម្ងន់សរុប ថែមទាំងអំពើល្មើសលើការផ្ទុកទម្ងន់អតិបរិមានៃភ្លៅនោះ ត្រូវធ្វើការផាកពិន័យទាំងពីរករណី ។

ក្នុងករណីដែលទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តល្មើសទៀត ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង និងបញ្ឈប់អាជីវកម្មដឹកជញ្ជូនរបស់ក្រុមហ៊ុនចំនួន ១(មួយ) ឆ្នាំ ។ ម្ចាស់យានយន្តត្រូវទទួលខុសត្រូវលើការលើកដាក់ទំនិញ និងបង់ថ្លៃឈ្នួលកន្លែងទុកដាក់ថែទាំទំនិញ និងយានជំនិះដោយខ្លួនឯង ។

**មាត្រា ៦១.-**

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)
នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើសដែល មានចែងក្នុងមាត្រា ៦០ ខាងលើនេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដងចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៦០ ខាងលើនេះ ។ ក្នុងករណីដែលទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយនៅតែបន្តប្រព្រឹត្តល្មើសទៀត ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ ដូចមានចែងក្នុងវាក្យខណ្ឌទី ១ នៃកថាខណ្ឌនេះ ។

**មាត្រា ៦២.-**

ជនណាដែលមិនគោរពតាមការបញ្ជារបស់ភ្នាក់ងារសុវត្ថិភាព ដែលប្រចាំការតាមគោលដៅ ដូចមានចែងក្នុងមាត្រា២៧ នៃច្បាប់នេះ ត្រូវពិន័យអន្តរការណ៍ជា ប្រាក់ចំនួន ១០ ០០០ (មួយម៉ឺន)រៀល ។

**មាត្រា ៦៣.-**

ជនណាសាងសង់របារកាត់ទទឹង ឬទួលបន្ថយល្បឿន ឬវត្ថុប្រហាក់ប្រហែល ពីលើផ្លូវថ្នល់ដោយគ្មានការអនុញ្ញាត ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ១ ០០០ ០០០(មួយលាន)រៀល និងតម្រូវឲ្យរុះរើឧបករណ៍ដែលសាងសង់នោះចេញ ។

**មាត្រា ៦៤.-**

ជនណាដែលធ្វើកិច្ចការសាធារណការទាំងឡាយនៅក្នុងតួផ្លូវ ទ្រូងផ្លូវ ជាយផ្លូវ គែមផ្លូវ និងដីនៅសល់ នៃដីចំណីផ្លូវដោយគ្មានការអនុញ្ញាតពីសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ៥០០ ០០០(ប្រាំសែន)រៀល ។

**មាត្រា ៦៥.-**

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែល

មានចែងក្នុងមាត្រា ៦៤ ខាងលើនេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ចំនួន ១ ០០០ ០០០(មួយលាន)រៀល ។

**មាត្រា ៦៦.-**

ជនណាដែលធ្វើនូវការប្រើដីចំណីផ្លូវសម្រាប់ធ្វើផ្លូវចេញចូលគេហដ្ឋាន អាគារ រោងចក្រសហគ្រាសឬកន្លែងផ្សេងៗ ដែលជាប់ផ្លូវថ្នល់ដោយគ្មានការអនុញ្ញាតពីសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ៥០ ០០០(ប្រាំម៉ឺន)រៀល ។

ក្នុងករណីដែលទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តល្មើសទៀត ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង ។

**មាត្រា ៦៧.-**

ជនណាដែលធ្វើឲ្យផ្លូវថ្នល់រអិល ស្អិត ចាក់គំនរសំណង់ពង្រាយលើផ្លូវថ្នល់ ឬដាក់សម្ភារៈវត្ថុរាយប៉ាយលើផ្លូវថ្នល់ និងដាក់តាំងសម្ភារៈ ឬស្លាកសញ្ញាផ្សេងៗធ្វើឲ្យបាំងភ្នែកអ្នកបើកបរ ឬបង្កឧបសគ្គដល់អ្នកថ្មើរជើងក្នុងការធ្វើដំណើរ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ៥០ ០០០(ប្រាំម៉ឺន)រៀល ។

ក្នុងករណីដែលទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តល្មើសទៀត ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង ។

**មាត្រា ៦៨.-**

ជនណាដែលផ្លាស់ប្តូរ រុះរើ ចល័ត សរសេរ ឬធ្វើឲ្យខូចប្រយោជន៍ដល់ស្លាកសញ្ញាចរាចរណ៍ ភ្លើងសញ្ញាចរាចរណ៍ របងការពារសុវត្ថិភាព បង្គោលគីឡូម៉ែត្រ សញ្ញាបង្ហាញទិសត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ១០០ ០០០(មួយសែន)រៀល ។

ក្នុងករណីដែលទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តល្មើសទៀត ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង ។

**មាត្រា ៦៩.-**

ជនណាប្រកបអាជីវកម្មលើវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ការថែទាំនិងការបើកមន្ទីរពិសោធវិស័យផ្លូវថ្នល់ដោយគ្មានអាជ្ញាបណ្ណ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ៥ ០០០ ០០០(ប្រាំលាន)រៀល ។

ក្នុងករណីដែលទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តល្មើសទៀត ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង ។

**មាត្រា ៧០.-**

ជនណាដែល ៖

១- រៀបចំសកម្មភាពនិងពិធីផ្សេងៗនៅលើដងផ្លូវថ្នល់ គ្មានការអនុញ្ញាតពីរដ្ឋបាលថ្នាក់ក្រោម

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ជាតិត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ១០០ ០០០(មួយសែន)រៀល ។

២- រៀបចំសកម្មភាពនិងពិធីផ្សេងៗនៅលើដងផ្លូវថ្នល់គ្មានឬមានការអនុញ្ញាតពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងបណ្តាលឲ្យខូចខាតដោយអចេតនាដល់ផ្លូវថ្នល់ ឬបរិក្ខារផ្លូវថ្នល់ត្រូវតម្រូវឲ្យធ្វើការជួសជុលឡើងវិញឲ្យដូចស្ថានភាពដើម និងត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១៩(បទធ្វើឲ្យខូចខាតផ្សេងទៀត ដោយខ្វះការប្រុងប្រយ័ត្ន ឬការមិនគោរពបទបញ្ជា)នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៧១.-**

ជនណាដែលសាងសង់ដោយខុសច្បាប់នូវសំណង់រឹងមាំ មានលក្ខណៈជាអចិន្ត្រៃយ៍នៅលើដីសម្រាប់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ត្រូវព្រមានជាលាយលក្ខណ៍អក្សរ និងតម្រូវឲ្យរុះរើចេញនូវសំណង់នោះ ។

ក្នុងករណីរឹងទទឹង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី ១០០ ០០០(មួយសែន)រៀល ទៅ ២ ០០០ ០០០(ពីរលាន)រៀល ។

**មាត្រា ៧២.-**

ជនណាដែលសាងសង់សំណង់ផ្សេងៗ ដោយមិនបានគោរពតាមចំណុចទី១ និងចំណុចទី២ នៃមាត្រា ៣០ នៃច្បាប់នេះត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០ ០០០(មួយសែន)រៀលទៅ ១ ០០០ ០០០(មួយលាន)រៀល និងតម្រូវឲ្យរុះរើចេញនូវសំណង់នោះ ។

ក្នុងករណីរឹងទទឹង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ) ខែទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០(មួយលាន)រៀល ទៅ ៤ ០០០ ០០០(បួនលាន)រៀល ។

**មាត្រា ៧៣.-**

ជនណាដែលកែប្រែឬបង្វែរផ្លូវថ្នល់ និងលើក ឬបើកផ្លូវថ្នល់តភ្ជាប់ទៅផ្លូវធំ ដោយគ្មានការអនុញ្ញាតពីសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ត្រូវពិន័យជាប្រាក់ពី ១ ០០០ ០០០(មួយលាន)រៀល ទៅ ៤ ០០០ ០០០(បួនលាន)រៀល ។

ក្នុងករណីរឹងទទឹង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ) ខែទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០(មួយលាន)រៀល ទៅ ៤ ០០០ ០០០(បួនលាន)រៀល ។

**មាត្រា ៧៤.-**

ជនណាដែលទន្ទ្រាន គ្រួតត្រា ប្រើប្រាស់ ដោយសាងសង់សំណង់ ឬការប្រទាំងឡាយបំពានលើដីផ្លូវថ្នល់ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០ ០០០(មួយសែន) រៀល ទៅ ១ ០០០ ០០០(មួយលាន)រៀល និងតម្រូវឲ្យរុះរើចេញនូវសំណង់ឬការប្រទាំងឡាយនោះ ។

ក្នុងករណីរឹងទទឹង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែទៅ២(ពីរ)ឆ្នាំ និងពិន័យ

ROYAUME DU CAMBODGE LE MINISTRE du PALAIS ROYAL

ជាប្រាក់ពី ១ ០០០ ០០០(មួយលាន)រៀល ទៅ៤ ០០០ ០០០(បួនលាន)រៀល ។

**មាត្រា ៧៥.-**

អ្នកប្រើប្រាស់យានយន្តដឹកជញ្ជូនធុនធ្ងន់ដឹកជញ្ជូនទំនិញលើផ្លូវថ្នល់ ដែលផ្ទុកលើសទម្ងន់ដែលធ្វើឲ្យស្រុតផ្លូវថ្នល់ឬបែកលូកាត់ទទឹងផ្លូវ ឬបាក់ស្ពានត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ) ខែ ទៅ ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០(មួយលាន)រៀល ទៅ ៤ ០០០ ០០០ (បួនលាន)រៀល ។

មន្ត្រីមានសមត្ថកិច្ចដែលអនុញ្ញាតឲ្យរថយន្តផ្ទុកលើសទម្ងន់ ធ្វើចរាចរណ៍លើបណ្តាញផ្លូវថ្នល់ ហើយបណ្តាលឲ្យស្រុតផ្លូវថ្នល់ ឬបែកលូកាត់ទទឹងផ្លូវ ឬបាក់ស្ពាន ត្រូវផ្តន្ទាទោសដូចគ្នាដែរ ។

**មាត្រា ៧៦.-**

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុង មាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៧៥ ខាងលើនេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥ ០០០ ០០០(ប្រាំលាន)រៀល ទៅ ១០ ០០០ ០០០ (ដប់លាន)រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើនដូចតទៅនេះ ៖

១- ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយនីតិបុគ្គលនិងការជម្រះបញ្ជីនៃនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ។

២- ការដាក់ឲ្យស្ថិតក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមព្រហ្មទណ្ឌ ។

៣- ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមព្រហ្មទណ្ឌ ។

៤- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ តាមបែបបទកំណត់ដោយមាត្រា ១៧៣ (ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ) នៃក្រមព្រហ្មទណ្ឌ ។

៥- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមព្រហ្មទណ្ឌ ។

៦- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមគ្រប់

មធ្យោបាយ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៧៧.-**

ជនណាដែលធ្វើកិច្ចការសាធារណការទាំងឡាយដោយគ្មានការអនុញ្ញាតពីសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ និងបណ្តាលឲ្យខូចខាតដល់តួផ្លូវ ទ្រូងផ្លូវ ជាយផ្លូវ គែមផ្លូវ និងដីនៅសល់នៃដីចំណីផ្លូវ ត្រូវតម្រូវឲ្យធ្វើការជួសជុលឡើងវិញឲ្យដូចស្ថានភាពដើមនិងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០(បួនលាន)រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ។

**មាត្រា ៧៨.-**

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៧៧ ខាងលើនេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០ ០០០ ០០០(ដប់លាន)រៀល ទៅ ២០ ០០០ ០០០ (ម្ភៃលាន)រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើនដូចតទៅនេះ ៖

១- ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយនីតិបុគ្គលនិងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

២- ការដាក់ឲ្យស្ថិតក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមព្រហ្មទណ្ឌ ។

៣- ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយឬច្រើនតាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមព្រហ្មទណ្ឌ ។

៤- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ តាមបែបបទកំណត់ដោយមាត្រា ១៧៣ (ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ) នៃក្រមព្រហ្មទណ្ឌ ។

៥- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមព្រហ្មទណ្ឌ ។

៦- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមគ្រប់មធ្យោបាយតាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមព្រហ្មទណ្ឌ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

## ជំពូកទី១២
## អន្តរប្បញ្ញត្តិ

**មាត្រា៧៩ .-**

លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យផ្លូវថ្នល់ ដែលនៅមានជាធរមាននៅមានសុពលភាព រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

**មាត្រា៨០ .-**

ក្រោយពីច្បាប់នេះចូលជាធរមានក្នុងរយៈពេល ០១(មួយ)ឆ្នាំ មន្ទីរពិសោធន៍ពាក់ព័ន្ធវិស័យផ្លូវថ្នល់ដែលបាននិងកំពុងប្រកបអាជីវកម្ម ត្រូវស្នើសុំអាជ្ញាបណ្ណស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

## ជំពូកទី១៣
## អវសានប្បញ្ញត្តិ

**មាត្រា៨១ .-**

ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលមានអានុភាពនៅកាលបរិច្ឆេទនៃការអនុវត្ត ហើយផ្ទុយនឹងបញ្ញត្តិនៃច្បាប់នេះ ត្រូវចាត់ទុកថាគ្មានអនុភាពត្រឹមទំហំដែលផ្ទុយនឹងច្បាប់នេះ ចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៤

**ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

នស/រកម.០៥១៤.០០៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ហត្ថលេខា**

**ត្រាំ អ៊ីវតឹក**

លេខ: ៥៧៥ ស.ណ

**សំអាងថាចម្លងត្រឹមត្រូវតាមច្បាប់ដើម**

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៤

**...រាជរដ្ឋាភិបាល**

**សយ សុខា**

# សទ្ទានុក្រម

១- **ផ្លូវថ្នល់ ហៅថាផ្លូវ** សំដៅដល់ទំហំផ្លូវទាំងមូលរួមមានតួផ្លូវ ទ្រូងផ្លូវ ជាយផ្លូវ ឬចិញ្ចើមផ្លូវ ស្ពាន ស្ពានអាកាស ស្ពានរំលង ផ្លូវរូង និងកំពង់ចម្លងតភ្ជាប់ផ្លូវថ្នល់។

២- **ទ្រូងផ្លូវ** សំដៅដល់ចំណែកនៃផ្លូវ ទុកសម្រាប់ឲ្យយានជំនិះគ្រប់ប្រភេទធ្វើចរាចរណ៍។

៣- **គន្លងផ្លូវ** សំដៅដល់ចំណែកមួយនៃទ្រូងផ្លូវ ខណ្ឌដោយគំនូសឬបរិក្ខារបែងចំណែកផ្លូវ តាមបណ្តោយទ្រូងផ្លូវ ដែលមានទទឹងគ្រប់គ្រាន់អាចឲ្យយានជំនិះគ្រប់ប្រភេទធ្វើចរាចរណ៍បានមួយជួរ។

៤- **ផ្លូវថ្មើរជើង** សំដៅដល់ផ្នែកមួយនៃផ្លូវថ្នល់ដែលធ្វើឬរៀបចំឡើងសម្រាប់ឲ្យមនុស្សដើរប្រកបដោយសុវត្ថិភាព។

៥- **ជាយផ្លូវ** សំដៅដល់ផ្នែកសងខាងនៃទ្រូងផ្លូវនៅក្រៅទីប្រជុំជន ដែលយានជំនិះអាចចតនៅទីនោះបានក្នុងករណីចាំបាច់។

៦- **ចិញ្ចើមផ្លូវ** សំដៅដល់ផ្នែកសងខាងនៃទ្រូងផ្លូវនៅក្នុងទីប្រជុំជន ដែលរៀបចំទុកសម្រាប់ថ្មើរជើងធ្វើដំណើរ ដាំដើមឈើ និងបង្កប់បរិក្ខារបម្រើផលប្រយោជន៍សេវាសាធារណៈ។

៧- **រង្វង់មូល** សំដៅដល់កន្លែងផ្លូវប្រសព្វដែលនៅចំកណ្តាលមានខឿនជារាងរង្វង់មូល មានផ្លាកសញ្ញាបង្ហាញទិសចរាចរណ៍ និងមានទ្រូងផ្លូវឯកទិសព័ទ្ធជុំវិញដោយសញ្ញាព្រួញប្រាប់ទិសចរាចរណ៍។

៨- **កំពង់ចម្លង** សំដៅដល់បរិវេណផ្ទៃដីកំណត់ជាក់លាក់នៅជាប់មាត់ទឹកឬទីលានកំពង់ចម្លងដែលត្រូវបានរៀបចំឡើងប្រកបដោយសុវត្ថិភាពសម្រាប់ការដឹកជញ្ជូន និងការធ្វើដំណើរឆ្លងពីត្រើយម្ខាងទៅម្ខាងទៀតនៃព្រែក បឹង ស្ទឹង ទន្លេ ដៃសមុទ្រ ដោយប្រើប្រាស់ផែចម្លងឬស្ពានចម្លង ដោយមានយានចម្លងដូចជាទូក ស្រឡាង ស្រឡាងអូស។ល។ ទីលានកំពង់ចម្លងត្រូវបានរៀបចំដោយសាងសង់បណ្តាញផ្លូវឡើងចុះ ទីឈប់រថយន្តរង់ចាំ កន្លែងរង់ចាំសម្រាប់អ្នកធ្វើដំណើរ មានភ្នាក់ងារគ្រប់គ្រងចាត់ចែងបញ្ហាចរាចរណ៍ និងបរិក្ខារផ្សេងៗបម្រើឲ្យកំពង់ចម្លង។

៩- **បរិក្ខារផ្លូវថ្នល់** សំដៅដល់ទីចំណត ទីសំចត ភ្លើងសញ្ញា ផ្លាកសញ្ញាកំណត់ល្បឿន ផ្លាកសញ្ញាបង្ហាញផ្លូវ សញ្ញាចន្លោះគម្លាត គំនូសសញ្ញា ឬរបាំង ឬបរិក្ខារបែងចំណែកផ្លូវ

រង្វង់មូល ខឿនបែងចែកទិសចរាចរណ៍ ថ្មចិញ្ចើមផ្លូវ ជញ្ជាំង របងការពារ បង្គោលគីឡូម៉ែត្រ បង្គោលសញ្ញាកំណត់ព្រំ ព្រមទាំងផ្លាកសញ្ញា និងឧបករណ៍បំពាក់ផ្សេងទៀតនៅតាមបណ្តោយផ្លូវថ្នល់។

១០- **បរិក្ខារសម្រួលការបង្ហូរទឹក** សំដៅដល់ប្រឡាយ ស្នាមភ្លោះ អាងស្តុកទឹក ស្ថានីយចម្រោះទឹកកខ្វក់ ទីជម្រាល ឬចំណោត។ល។ ដែលបានរៀបចំនៅតាមបណ្តោយផ្លូវថ្នល់ សម្រាប់ការពារផ្លូវថ្នល់ បរិក្ខារផ្លូវថ្នល់ សុវត្ថិភាពចរាចរណ៍។

១១- **បរិក្ខារបែងចំណែកផ្លូវ** សំដៅដល់បរិក្ខារសម្រាប់បែងចែកទ្រូងផ្លូវជាពីរចំណែកឲ្យចរាចរណ៍ទៅមក ឬបែងចែកចំណែកនោះជាគន្លងផ្លូវ។ បរិក្ខារបែងចំណែកផ្លូវមានជាប្រភេទចល័តនិងអចល័ត។

១២- **សំណង់សិល្បការ្យ** សំដៅដល់សំណង់ស្ពាន លូ ជញ្ជាំងទប់ដី ប្រព័ន្ធរំដោះទឹក និងសំណង់រូបវន្តផ្សេងទៀតដែលផ្តល់សុវត្ថិភាព ប្រសិទ្ធភាព និងស្ថិរភាពដល់ផ្លូវថ្នល់។

១៣- **សំណង់ផ្លូវថ្នល់** សំដៅដល់ផ្លូវថ្នល់ កន្លែងឈប់យានជំនិះ ចំណតរថយន្តលើផ្លូវ បរិក្ខារផ្លូវថ្នល់ សំណង់សិល្បការ្យ និងសំណង់ផ្សេងៗទៀតបម្រើឲ្យផ្លូវថ្នល់។

១៤- **ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់** សំដៅដល់ដីចំណីផ្លូវ សំណង់ផ្លូវថ្នល់ ស្ថានីយចំណតរថយន្ត (បេនឡាន) បរិវេណចំណតរថយន្ត ទីសំចតរថយន្ត ស្ថានីយសេវាតាមដងផ្លូវ និងទីតាំងសម្រាកលំហែ។

១៥- **ដីចំណីផ្លូវថ្នល់** សំដៅដល់ដីនៅសងខាងខ្សែបន្ទាត់ផ្ចិតនៃផ្លូវថ្នល់ ព្រមទាំងទំហំចំណីផ្លូវថ្នល់ ទុកបម្រុងសម្រាប់ការគ្រប់គ្រង ការអភិវឌ្ឍ និងការការពារផ្លូវថ្នល់ ធានាសុវត្ថិភាពចរាចរណ៍ និងសម្រាប់ការប្រើប្រាស់ការងារហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងទៀត ដែលកំណត់ដោយខ្សែបន្ទាត់ព្រំដីចំណីផ្លូវ។

១៦- **ខ្សែបន្ទាត់ព្រំដីចំណីផ្លូវថ្នល់** សំដៅដល់ខ្សែបន្ទាត់នៃបណ្តាចំណុចព្រំដីចំណីផ្លូវ ដែលមានចម្ងាយកំណត់ពីខ្សែបន្ទាត់ផ្ចិតនៃផ្លូវថ្នល់។

១៧- **ទំហំផ្លូវកម្រិតកំណត់** សំដៅដល់ទំហំមានខ្នាតកម្រិតកំណត់អំពីកម្ពស់និងផ្ទៃរបស់ផ្លូវស្ពាន កំពង់ចម្លង ផ្លូវរូង។ល។ ដើម្បីឲ្យរថយន្តដឹកជញ្ជូនទំនិញឆ្លងកាត់មានសុវត្ថិភាព។

ii

១៨- **កន្លែងផ្លូវប្រសព្វ** សំដៅដល់កន្លែងប្រសព្វនៃផ្លូវពីរឬច្រើន ដែលមានផ្ទៃរាបតែមួយ និងមិនកំណត់មុំនៃអ័ក្សរបស់ទ្រូងផ្លូវឡើយ។ កន្លែងផ្លូវប្រសព្វអាចមានរាងជា +, X, Y, T ឬរង្វង់មូលជាដើម។

១៩- **កន្លែងផ្លូវប្រសព្វក្នុងលំហ** សំដៅដល់កន្លែងប្រសព្វនៃផ្លូវពីរឬច្រើន ដែលមានកម្រិតកម្ពស់ផ្ទៃខុសគ្នានិងមិនកំណត់មុំនៃអ័ក្សរបស់ទ្រូងផ្លូវឡើយ។ ផ្លូវប្រសព្វក្នុងលំហអាចមានរាងជា +, X, និង★។

២០- **ទម្ងន់សរុបអនុញ្ញាតអតិបរមារបស់យាន** សំដៅដល់ផលបូកទម្ងន់យាននឹងទម្ងន់ផ្ទុកមនុស្សនិងទម្ងន់ផ្ទុកទំនិញ។ ប្រសិនបើយានមានសណ្តោង ទម្ងន់សរុបអនុញ្ញាតអតិបរមារបស់យាន គឺផលបូកនៃទម្ងន់សរុបអតិបរមារបស់យាននីមួយៗ។

២១- **ផ្លូវល្បឿនលឿន** សំដៅដល់ផ្លូវសម្រាប់យានយន្តធ្វើចរាចរណ៍ មានបរិក្ខារចែកទ្រូងផ្លូវជាពីរចំណែកខុសទិសគ្នាឬចែកជាគន្លងផ្លូវ គ្មានកន្លែងផ្លូវប្រសព្វលើផ្ទៃរាបមួយ ឬត្រូវមានផ្លូវប្រសព្វតិចបំផុតក្នុងករណីចាំបាច់ និងបំពាក់គ្រប់គ្រាន់នូវបរិក្ខារផ្លូវថ្នល់ ដើម្បីធានាលំហូរចរាចរណ៍អត់ឈប់ សុវត្ថិភាព និងដើម្បីបន្ថយពេលវេលាធ្វើដំណើរ និងមានកន្លែងកំណត់សម្រាប់ឲ្យយានយន្តចេញនិងចូលផ្លូវល្បឿនលឿន។

២២- **អ្នកប្រើប្រាស់ផ្លូវថ្នល់** សំដៅដល់អ្នកបើកបរយាន អ្នកថ្មើរជើង អ្នកធ្វើអាជីវកម្មលើផ្លូវថ្នល់ អ្នកឃ្វាលឬអ្នកប្រើប្រាស់សត្វពាហនៈ និងអ្នកប្រើប្រាស់ផ្លូវថ្នល់ក្នុងគោលបំណងផ្សេងទៀត។

២៣- **ផ្លូវជាតិ** សំដៅដល់ផ្លូវដែលមានចរាចរណ៍ច្រើន៖

ក- ផ្លូវភ្ជាប់ចេញពីរាជធានីភ្នំពេញឆ្ពោះទៅកាន់ក្រុងនៃខេត្តនីមួយៗនៅទូទាំងប្រទេស។

ខ- ផ្លូវភ្ជាប់ចេញពីក្រុងនៃខេត្តមួយ ឆ្ពោះទៅកាន់ក្រុងនៃខេត្តមួយទៀត។

គ- ផ្លូវភ្ជាប់ចេញពីផ្លូវជាតិ ឆ្ពោះទៅកាន់ផ្លូវជាតិ។

ឃ- ផ្លូវបែកចេញពីផ្លូវជាតិ ឆ្ពោះទៅកាន់ក្រុងនៃខេត្តមួយ។

ង- ផ្លូវបែកចេញពីផ្លូវជាតិ ឬផ្លូវភ្ជាប់ចេញពីក្រុងនៃខេត្តមួយឆ្ពោះទៅកាន់តំបន់សំខាន់ៗ ដូចជា កំពង់ផែ ស្ថានីយរថភ្លើង អាកាសយានដ្ឋាន តំបន់សេដ្ឋកិច្ចពិសេស រមណីយដ្ឋានទេសចរណ៍ ច្រកទ្វារព្រំដែន តំបន់មានសក្តានុពលសេដ្ឋកិច្ចសំខាន់ៗផ្សេងទៀត។

ច- ផ្លូវសំខាន់ៗរបស់ជាតិ មានចរាចរណ៍ច្រើនដែលកំណត់ដោយរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន។

២៤- **ផ្លូវខេត្ត** សំដៅដល់ផ្លូវដែលមានចរាចរណ៍មធ្យមៈ

ក- ផ្លូវភ្ជាប់ចេញពីក្រុងនៃខេត្តមួយ ឆ្ពោះទៅកាន់ទីរួមស្រុក ខណ្ឌ។

ខ- ផ្លូវបែកចេញពីផ្លូវជាតិ ឆ្ពោះទៅកាន់ផ្លូវខេត្ត ។

គ- ផ្លូវបែកចេញពីផ្លូវខេត្តឬផ្លូវក្រុង ឆ្ពោះទៅកាន់ទីរួមស្រុក ខណ្ឌ។

ឃ- ផ្លូវភ្ជាប់ចេញពីក្រុងនៃខេត្តមួយ ឆ្ពោះទៅកាន់ផ្លូវខេត្ត ។

ង- ផ្លូវបែកចេញពីផ្លូវខេត្ត ឆ្ពោះទៅកាន់ផ្លូវខេត្ត។

ច- ផ្លូវបែកចេញពីផ្លូវខេត្ត ឬផ្លូវក្រុង ឬផ្លូវទីប្រជុំជននានាក្នុងខេត្តទៅកាន់តំបន់សំខាន់ៗ ដូចជា កំពង់ផែ ស្ថានីយរថភ្លើង អាកាសយានដ្ឋាន តំបន់សេដ្ឋកិច្ចពិសេស រមណីយដ្ឋានទេសចរណ៍ ច្រកទ្វារព្រំដែនទ្វេភាគី តំបន់មានសក្តានុពលសេដ្ឋកិច្ចមធ្យមផ្សេងទៀត។

២៥- **ផ្លូវរាជធានី ផ្លូវក្រុង និងផ្លូវទីប្រជុំជននានាក្នុងខេត្ត** សំដៅដល់ផ្លូវថ្នល់ដែលស្ថិតនៅក្នុងបរិវេណភូមិសាស្ត្ររដ្ឋបាលរាជធានី ខេត្ត ដោយរួមមានទ្រូងផ្លូវ ចិញ្ចើមផ្លូវ និងផ្លូវថ្មើរជើង។

២៦- **ផ្លូវជនបទ** សំដៅដល់ៈ

ក- ផ្លូវដែលភ្ជាប់ពីផ្លូវជាតិ ផ្លូវខេត្ត ឆ្ពោះទៅកាន់ក្រុង ទីរួមស្រុក ខណ្ឌ ទីប្រជុំជនឃុំ សង្កាត់ និងទៅភូមិ។

ខ- ផ្លូវដែលភ្ជាប់ពីក្រុង ទីរួមស្រុក ខណ្ឌ ឆ្ពោះទៅកាន់ក្រុង ទីរួមស្រុក ខណ្ឌ។

គ- ផ្លូវដែលភ្ជាប់ពីក្រុង ទីរួមស្រុក ខណ្ឌ ទៅទីប្រជុំជនឃុំ សង្កាត់។

ឃ-ផ្លូវដែលភ្ជាប់ពីទីប្រជុំជនឃុំ សង្កាត់ ទៅទីប្រជុំជនឃុំ សង្កាត់។

ង- ផ្លូវដែលភ្ជាប់ពីទីប្រជុំជនឃុំ សង្កាត់ ទៅភូមិ។

ច- ផ្លូវដែលភ្ជាប់ពីភូមិទៅភូមិ។

ឆ- ផ្លូវក្នុងភូមិ។

២៧- **ស្ថានីយចំណតរថយន្ត** សំដៅដល់កន្លែងចតរថយន្ត សម្រាប់សកម្មភាពឡើងចុះអ្នកដំណើរ និងលើកដាក់ទំនិញ។

២៨- **ស្ថានីយថ្លឹងយានយន្ត** សំដៅដល់កន្លែងដែលរៀបចំឡើងសម្រាប់ត្រួតពិនិត្យទម្ងន់យានយន្ត។

២៩- **បទប្បញ្ញត្តិបច្ចេកទេស** សំដៅដល់បទដ្ឋានបច្ចេកទេស ស្តង់ដាបច្ចេកទេស និងឯកសារណែនាំលំអិតបច្ចេកទេសការងារ លក្ខខណ្ឌសុវត្ថិភាពការងារ និងលក្ខខណ្ឌសុវត្ថិភាពចរាចរណ៍។

៣០- **អ្នកជាប់ពាក់ព័ន្ធផ្លូវថ្នល់** សំដៅដល់អ្នកគ្រប់គ្រង អ្នកសាងសង់ អ្នកត្រួតពិនិត្យ អ្នកផ្តល់ហិរញ្ញប្បទាន ឬសម្បទានិកអភិវឌ្ឍន៍និងថែទាំផ្លូវថ្នល់ អ្នកដឹកជញ្ជូន និងអ្នកប្រើប្រាស់ ផ្លូវថ្នល់ អ្នករស់នៅសងខាងផ្លូវថ្នល់ អ្នកផ្គត់ផ្គង់សម្ភារៈ គ្រឿងចក្រ បរិក្ខារផ្លូវថ្នល់។

៣១- **ស្ថានីយសេវាតាមដងផ្លូវ** សំដៅដល់កន្លែងបម្រើដល់ចរាចរណ៍តាមដងផ្លូវដូចជា ស្ថានីយប្រេងឥន្ធនៈ កន្លែងគ្រប់គ្រងនិងផ្តល់ព័ត៌មាន ទីតាំងសម្រាកលំហែ ទីសម្រាក យានដ្ឋានជួសជុលយានយន្ត។ល។

៣២- **ស្ថានីយសម្រាក** សំដៅដល់កន្លែងសម្រាប់ឱ្យអ្នកធ្វើដំណើរសម្រាក ដោយមានសេវា អាហារដ្ឋាន បង្គន់អនាម័យ កន្លែងជូនដំណឹង។

៣៣- **ទីតាំងសម្រាកលំហែ** សំដៅដល់កន្លែងសម្រាប់ធ្វើសេវាកម្មសាធារណៈ ដែលស្ថិតនៅ ខាងក្រៅដីចំណីផ្លូវនៃផ្លូវថ្នល់ធំៗដូចជា ផ្លូវល្បឿនលឿន ផ្លូវជាតិ សម្រាប់ឱ្យអ្នកបើកបរ និងអ្នកធ្វើដំណើរឈប់សម្រាក ដោយមានសណ្ឋាគារ ភោជនីយដ្ឋាន មានបណ្តាញ ផ្លូវថ្នល់សុវត្ថិភាព មានចំណតរថយន្ត ស្ថានីយប្រេងឥន្ធនៈ ស្ថានីយផ្តល់ព័ត៌មាន យានដ្ឋានជួសជុលយានយន្ត មានបណ្តាញទឹកស្អាត ប៉ុន្តែមិនមែនជារមណីយដ្ឋានទេ។

៣៤- **ផ្លូវជាន់គ្នា** សំដៅដល់ផ្លូវពីរឬច្រើនស្ថិតនៅលើផ្ទៃរាបតែមួយ ឬស្ថិតនៅលើផ្ទៃខុស កម្រិតគ្នា មានទិសស្របគ្នា មានប្រភេទនិងមុខងារផ្លូវខុសគ្នា។

៣៥- **ស្ពាន** សំដៅដល់សំណង់ឆ្លងផ្ទៃទឹក សម្រាប់ចម្លងចរាចរណ៍ពីទីតាំងមួយទៅទីតាំងមួយ ទៀត។

៣៦- **ស្ពានអាកាស** សំដៅដល់ស្ពានឆ្លងផ្ទៃដី សម្រាប់ចម្លងចរាចរណ៍ពីទីតាំងមួយទៅទីតាំងមួយ ទៀត ដោយរំលងសំណង់គ្រប់ប្រភេទ នៅទីតាំងខុសៗគ្នា កម្រិតកម្ពស់ខុសៗគ្នា។

៣៧- **ស្ពានរំលង** សំដៅដល់ស្ពានឆ្លងផ្ទៃដី សម្រាប់ចម្លងចរាចរណ៍ពីទីតាំងមួយទៅទីតាំងមួយ ទៀត ដោយរំលងផ្លូវថ្នល់ឬផ្លូវរថភ្លើងនៅទីតាំងតែមួយ។

៣៨- **ផ្លូវរូង** សំដៅដល់ខ្សែផ្លូវបម្រើឱ្យចរាចរណ៍ ស្ថិតនៅក្រោមផ្ទៃដីឬក្នុងរូង ដែលមានជញ្ជាំង សុវត្ថិភាព។

៣៩- **សំណៅ** សំដៅដល់ការចម្លងពីសេចក្តីដើម ច្បាប់ដើម ដើម្បីទុកជាឯកសារ។